ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# សេចក្តីប្រកាសព័ត៌មាន
# អ្នកនាំពាក្យក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា

- យោងតាមព័ត៌មានចំហជាសាធារណៈ ដែលបានចុះផ្សាយថា មានឧប្បត្តិហេតុ នៃការបាញ់យន្តហោះ ដែលបានធ្វើការហោះហើរគ្មានការអនុញ្ញាត នៅក្នុងលំហអាកាសយោធាកម្ពុជាហាមឃាត់ ។
- **អ្នកនាំពាក្យក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា** សូមប្រកាសជម្រាបជូនសាធារណជន និងរាល់បណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិ សូមបញ្ឈប់ជាបន្ទាន់ នូវការបកស្រាយ ឬបំផុសព័ត៌មានពាក់ព័ន្ធនឹងឧប្បត្តិហេតុនេះ គឺអាចបណ្តាលឲ្យមានការយល់ច្រឡំ និងការបកស្រាយខុសពីការពិត ពាក់ព័ន្ធដល់សន្តិសុខជាតិកម្ពុជា។
- **អ្នកនាំពាក្យក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា** សូមជម្រាបជូនសាធារណជនថា រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងការពារជាតិរបស់ខ្លួន កំពុងធ្វើការស៊ើបអង្កេត ចំពោះឧប្បត្តិហេតុដែលបានកើតឡើងនេះ។ ព័ត៌មានជាផ្លូវការ នឹងជម្រាបជូន នៅពេលការស៊ើបអង្កេតស៊ីជម្រៅនេះ ត្រូវបានបញ្ចប់ជាផ្លូវការ។
- **អ្នកនាំពាក្យក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា** សូមជម្រាប និងរំលឹកផងដែរថា កម្ពុជាគ្មានហេតុផលណា ដែលធ្វើឲ្យមានការប៉ះពាល់ ឬ រំខានដល់ សុវត្ថិ-ភាពនៃការហោះហើរស៊ីវិលនោះទេ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅក្នុងកាតព្វកិច្ច និងសិទ្ធិរបស់ខ្លួន ក្នុងកិច្ចការពារអធិបតេយ្យ នៃលំហអាកាសរបស់កម្ពុជា ដែលមិនត្រូវបានរំលោភ ឬ ឈ្លានពាននោះឡើយ។

*រាជធានីភ្នំពេញ,ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១២ ម៉ោង ១៩:០០នាទី*